**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ៥២២២ សហវ

*រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០១០*

**សូមគោរពជូន**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា**

**កម្មវត្ថុ:** របាយការណ៍ស្តីពីការអនុវត្តថវិកាឆមាសទី ១ ឆ្នាំ ២០១០ ។

**យោង:** មាត្រា ៣៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពរាយការណ៍ជូន **សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា** មេត្តាជ្រាបអំពីរបាយការណ៍ជាលក្ខណៈស្ថាប័ន ស្តីពីការអនុវត្តថវិកាឆមាសទី១ ឆ្នាំ ២០១០ ដូចខាងក្រោម ÷

## I. ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

១- ឆ្នាំ ២០០៩ កន្លងទៅនេះ តាមការគណនារបស់វិទ្យាស្ថានជាតិស្ថិតិ កំណើនសេដ្ឋកិច្ចអាចនឹងសម្រេចបានប្រមាណ ០,១% ធៀបនឹងការព្យាករណ៍ ២,១% នៅចុងឆ្នាំក្នុងពេលរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ប្រការនេះ គឺដោយសារគ្រោះធម្មជាតិ តែធ្ងន់ជាងនេះគឺដោយសារការរងឥទ្ធិពលអវិជ្ជមានពីខាងក្រៅតាំងពីចុងឆ្នាំ ២០០៨ រហូតមក ដូចជាកត្តាអតិផរណាខ្ពស់ ការធ្លាក់ចុះនូវការនាំចេញសំលៀកបំពាក់ និងចំនួនភ្ញៀវទេសចរ ព្រមទាំងការធ្លាក់ចុះនៃទីផ្សារអចលនទ្រព្យ ដោយសារវិបត្តិទីផ្សារហិរញ្ញវត្ថុអន្តរជាតិ និងឱនភាពសេដ្ឋកិច្ចពិភពលោក ដែលបណ្តាលឱ្យកំណើនសេដ្ឋកិច្ចនៃបណ្តាប្រទេសជាច្រើនមានការធ្លាក់ចុះរហូតដល់ក្រោមសូន្យ ។ សម្រាប់កម្ពុជា លទ្ធផលនៃកំណើនវិជ្ជមាននេះ បានមកដោយសារវិស័យកសិកម្មនៅតែរក្សាបាននូវកំណើន ៥,៤% ធៀបនឹងកំណើន ៥,៧% ក្នុងឆ្នាំ ២០០៨ វិស័យសេវាកម្មរក្សាបានកំណើនត្រឹម ២,៣% ធៀបនឹងកំណើន ៩% ក្នុងឆ្នាំ ២០០៨ (ដែលក្នុងនោះ អាជីវកម្មទេសចរណ៍បានកើនឡើងប្រមាណ ២,៩% ធៀបនឹង ១០% នៅក្នុងឆ្នាំ ២០០៨) រីឯវិស័យឧស្សាហកម្មបានថយចុះ ៩,៥% ធៀបនឹងកំណើន ៤% ក្នុងឆ្នាំ ២០០៨ (ក្នុងនោះ ផលិតផលវាយនភ័ណ្ឌបានថយចុះ ៩% ធៀបនឹងកំណើន ២,២% ក្នុងឆ្នាំ ២០០៨ និងផលិតផលសំណង់បានកើនឡើង ៥% ធៀបនឹង ៥,៨% ក្នុងឆ្នាំ ២០០៨) ។ ក្នុងឆ្នាំ ២០០៩ កន្លងទៅនេះ អតិផរណាមធ្យមប្រចាំឆ្នាំបានធ្លាក់ចុះរហូតដល់ -០,៦% បន្ទាប់ពីបានកើនឡើងរហូតដល់ ១៩,៧% នៅក្នុងឆ្នាំ ២០០៨ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

២- នៅដើមឆ្នាំ ២០១០ សកម្មភាពសេដ្ឋកិច្ចបានរើបឡើងវិញ បន្ទាប់ពីទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីកលិយុគវិបត្តិហិរញ្ញវត្ថុអន្តរជាតិ ពិសេសលើវិស័យឧស្សាហកម្ម និងសេវាកម្ម ។ ជាក់ស្តែង វិស័យកាត់ដេរ និងទេសចរណ៍ ដែលបានទទួលរងផលប៉ះពាល់ខ្លាំងជាងគេ និងទាញកំណើនសេដ្ឋកិច្ចឱ្យថយចុះនៅឆ្នាំ ២០០៩ បានកើនឡើងវិញនៅឆមាសទី ១ ឆ្នាំ ២០១០ កន្លងមកនេះ ។ បើប្រៀបធៀបនឹងឆមាសទី ១ ឆ្នាំ ២០០៩ ការនាំចេញផលិតផលកាត់ដេរបានកើនឡើង ១៣,២% ចំនួនភ្ញៀវទេសចរបរទេសមកទស្សនាកម្ពុជាបានកើនឡើង ១២,៤% ។ ទន្ទឹមនឹងនេះ វិស័យកសិកម្ម ក៏មានសកម្មភាពល្អដែរ ពិសេសខាងផ្នែកដំណាំស្រូវ និងដំណាំកៅស៊ូ ។ ការកើនឡើងសកម្មភាពសេដ្ឋកិច្ចក្នុងវិស័យទាំងនេះ គឺជាមូលដ្ឋានដែលរុញកំណើនសេដ្ឋកិច្ចជាតិនៅឆ្នាំ ២០១០ ។ ដោយឡែក តាមទិន្នន័យពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៅឆមាសទី ១ ឆ្នាំ ២០១០ ការនាំចេញសរុបបានកើនឡើង ១១,៣% ធៀបនឹងឆមាសទី ១ ឆ្នាំ ២០០៩ ចំណែកការនាំចូលបានកើនឡើង ១៥% ក្នុងរយៈពេលដូចគ្នា ។ តាមការប៉ាន់ប្រមាណនៅឆ្នាំ ២០១០ និនភាពគណនីចរន្តនៃជញ្ជីងទូទាត់នឹងថយមកត្រឹមប្រមាណ ៨,៤% នៃផសស ទាបជាងឆ្នាំ ២០០៩ ដែលមានរហូតដល់ ១០,១% នៃផសស។ ទុនបំរុងអាចនឹងសម្រេចបាន ២,៥ ពាន់លានដុល្លារ ឬស្មើនឹង ៤,៥ ខែ នៃការនាំចូល ។ តាមការព្យាករណ៍កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០១០ អាចនឹងសម្រេចបានទៅតាមគោលដៅ ដែលបានរំពឹងទុកក្នុងអត្រាកំណើនប្រមាណ ៥,៥% ។ អតិផរណាមធ្យមប្រចាំឆ្នាំ ២០១០ អាចនឹងកើនឡើងក្នុងរង្វង់ ៥% ដោយសារការងើបឡើងវិញនៃសេដ្ឋកិច្ច និងនិន្នាការកើនឡើងនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារពិភពលោក ។ ជាមួយគ្នានេះ ការរើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកនៅមានលក្ខណៈផុយស្រួយនៅឡើយ ដែលប្រការនេះអាចបង្កើតហានិភ័យចំពោះនិន្នាការកំណើននៃសេដ្ឋកិច្ចកម្ពុជា ។ ដូច្នេះទាមទារ ឱ្យមានការតាមដាន និងត្រួតពិនិត្យជាប្រចាំ ដើម្បីត្រៀមលក្ខណៈចាត់វិធានការទាន់ពេលវេលា និង ប្រកបដោយប្រសិទ្ធភាព ។

## II. ការអនុវត្តថវិកាឆមាសទី ១ ឆ្នាំ ២០១០

### ១-ការអនុវត្តចំណូល

៣- ចំណូលសរុបដែលកត់ត្រាដោយអគ្គនាយកដ្ឋានរតនាគារជាតិ នៅក្នុងឆមាសទី ១ ឆ្នាំ ២០១០ អនុវត្តបានចំនួន ២.៩០៨.០១១ លានរៀល គឺស្មើនឹង ៤៧,៦% នៃច្បាប់ហិរញ្ញវត្ថុ តែបើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នា គឺមានកំណើន ១៥,៨% (ដូចមានក្នុងតារាងឧបសម្ព័ន្ធ I ភ្ជាប់មកជាមួយ)។ ក្នុងនោះ ចំណូលចរន្តអនុវត្តបាន ២.៧៤៥.១៥៣ លានរៀល គឺស្មើនឹង ៤៨,២% នៃច្បាប់ហិរញ្ញវត្ថុ តែបើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នា គឺមានកំណើន ១៧,១% ដែលក្នុងនោះ ចំណូលសារពើពន្ធអនុវត្តបាន ២.២៣៧.៨៩៧ លានរៀល គឺស្មើនឹង ៤៦,២% នៃច្បាប់ហិរញ្ញវត្ថុ តែបើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នា គឺមានកំណើន ៩,៥% និងចំណូលមិនមែនសារពើពន្ធអនុវត្តបាន ៥០៧.២៥៧ លានរៀល គឺស្មើនឹង ៥៩,៥% នៃច្បាប់ហិរញ្ញវត្ថុ ហើយមានកំណើន ៦៩,៤% បើប្រៀបធៀបមកនឹង ការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នា ។ ដោយឡែក

ចំពោះចំណូលមូលធន អនុវត្តបាន ១៦២.៨៥៨ លានរៀល គឺស្មើនឹង ៣៩,៥% នៃច្បាប់ហិរញ្ញវត្ថុ ប៉ុន្តែបើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នាវិញ គឺបានថយចុះ ២,៦% ។

៤- បើពិនិត្យមើលរចនាសម្ព័ន្ធនៃចំណូលសារពើពន្ធឃើញថាៈ ចំណូលពន្ធក្នុងប្រទេស (ដែលមានសមាមាត្រ ៧៨,៩% នៃចំណូលសារពើពន្ធសរុប) អនុវត្តបាន ១.៧៥៤.១៧៨ លានរៀល គឺស្មើនឹង ៤៥,៩% នៃច្បាប់ហិរញ្ញវត្ថុ ពោលគឺមានកំណើន ៩% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នា។ ចំណូលពន្ធពាណិជ្ជកម្មក្រៅប្រទេស (ដែលមានសមាមាត្រ ២១,១% នៃចំណូលសារពើពន្ធសរុប) អនុវត្តបាន ៤៨៣.៧១៩ លានរៀល គឺស្មើនឹង ៤៧,៣% នៃច្បាប់ហិរញ្ញវត្ថុ ពោលគឺមានកំណើន ១១,៣% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នា ។ ចំពោះចំណូលពន្ធផ្ទាល់ (ដែលមានសមាមាត្រ ២០% នៃចំណូលសារពើពន្ធសរុប) អនុវត្តបាន ៤៣៥.១០៤ លានរៀល គឺស្មើនឹង ៤៤,៩% នៃច្បាប់ហិរញ្ញវត្ថុ ពោលគឺមានកំណើន ១,៩% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នា ។ រីឯចំណូលពន្ធប្រយោល (ដែលមានសមាមាត្រ ៨០% នៃចំណូលសារពើពន្ធសរុប) អនុវត្តបាន ១.៨០២.៧៩២ លានរៀល គឺស្មើនឹង ៤៦,៦% នៃច្បាប់ហិរញ្ញវត្ថុ ពោលគឺមានកំណើន ៦១,៤% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នា ។

៥- ទន្ទឹមនឹងនេះដែរ បើពិនិត្យមើលការអនុវត្តចំណូលដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ដែលបានកត់ត្រាចំណូលដោយអគ្គនាយកដ្ឋានរតនាគារជាតិ នៅក្នុងឆមាសទី ១ ឆ្នាំ ២០១០ មានដូចខាងក្រោម ÷

**(ក)**- ចំណូលគយ និង រដ្ឋាករ អនុវត្តបាន ១.២១៦.៣៣៨ លានរៀល គឺស្មើនឹង ៤៦,៨% នៃច្បាប់ហិរញ្ញវត្ថុ ពោលគឺមានកំណើន ៨,៩% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នា ។ ប៉ុន្តែបើមិនដកការឧបត្ថម្ភធនលើវិស័យកសិកម្ម សុខាភិបាល និងអគ្គិសនី ចំណូលនេះអាចអនុវត្តបានរហូតដល់ ១.៤០៤.០០០ លានរៀល ពោលគឺស្មើនឹង ៥៤% នៃច្បាប់ហិរញ្ញវត្ថុ ។

**(ខ)**- ចំណូលពន្ធដារ អនុវត្តបាន ៩៣៥.២១៩ លានរៀល គឺស្មើនឹង ៤៥% នៃច្បាប់ហិរញ្ញវត្ថុ ពោលគឺមានកំណើន ១២,៦% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នា ។

៦- ចំណូលមិនមែនសារពើពន្ធ អនុវត្តបាន ៥០៧.២៥៧ លានរៀល គឺស្មើនឹង ៥៩,៥% នៃច្បាប់ហិរញ្ញវត្ថុ ពោលគឺមានកំណើន ៦៩,៤% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នា ។

**២-ការអនុវត្តចំណាយ**

៧- ចំណាយសរុបឆ្លងកាត់រតនាគារជាតិ នៅក្នុងឆមាសទី ១ ឆ្នាំ ២០១០ ដោយគិតទាំងការអនុវត្តតាមអាណត្តិបើកប្រាក់ និងការអនុវត្តតាមបុរេប្រទាន គឺអនុវត្តបានចំនួន ២.៧៣១.២៤០ លានរៀល គឺស្មើនឹង ៤៣,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺមានកំណើន ១៧,៧% ធៀបនឹងការអនុវត្តឆ្នាំ២០០៩ ក្នុងរយៈពេលដូចគ្នា។ ចំណាយចរន្តអនុវត្តបាន ២.០៩២.៥០៩ លានរៀល គឺស្មើនឹង ៤១,៦%នៃច្បាប់ហិរញ្ញវត្ថុ ពោលគឺមានកំណើន ១៥,២% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នា ដែលក្នុងនោះ ចំណាយបន្ទុកបុគ្គលិកអនុវត្តបាន ៩៣៦.០៨៩ លានរៀល គឺស្មើនឹង ៤៤,៨% នៃច្បាប់ហិរញ្ញវត្ថុ គឺមានកំណើន ១១% ពោលគឺស្មើនឹង ៤៦,៤% នៃចំណាយចរន្តសរុប បើគិតសម្រាប់ឆមាសទី ១ ឆ្នាំ ២០១០ នេះ និងចំណាយក្រៅពីបន្ទុកបុគ្គលិក

អនុវត្តបាន ១.១៥៦.៤២០ លានរៀល គឺស្មើនឹង ៣៩,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺមានកំណើន ១៨,៧% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នា ។ រីឯចំណាយមូលធនវិញ អនុវត្តបាន ៦៣៨.៧៣១ លានរៀល គឺស្មើនឹង ៥០,៣% នៃច្បាប់ហិរញ្ញវត្ថុ គឺមានកំណើន ២៦,៧% ធៀបនឹងការអនុវត្តក្នុងឆមាសទី ១ ឆ្នាំ ២០០៩ ដែលក្នុងនោះ ចំណាយវិនិយោគក្នុងប្រទេស អនុវត្តបាន ៥៧១.០៨៦ លានរៀល គឺស្មើនឹង ៥០,៩% នៃច្បាប់ហិរញ្ញវត្ថុ គឺមានកំណើន ២៧% និងចំណាយរំលស់បំណុលអនុវត្តបាន ៦៧.៦៤៥ លានរៀល គឺស្មើនឹង ៤៥,១% នៃច្បាប់ហិរញ្ញវត្ថុ គឺមានកំណើន ២៣,៤% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ក្នុងរយៈពេលដូចគ្នា ។

៨- ប្រសិនបើពិនិត្យមើលការអនុវត្តចំណាយចរន្តតាមវិស័យ (ដូចមានក្នុងតារាងឧបសម្ព័ន្ធ II-ក ជូនភ្ជាប់មកជាមួយ) ឃើញថា វិស័យរដ្ឋបាលទូទៅ អនុវត្តបាន ៣៩៥.៨៤៩ លានរៀល គឺស្មើនឹង ៥៧% នៃច្បាប់ហិរញ្ញវត្ថុ វិស័យការពារជាតិ និងសន្តិសុខអនុវត្តបាន ៤៨០.៤១៣ លានរៀល គឺស្មើនឹង ៤១,៨% នៃច្បាប់ហិរញ្ញវត្ថុ វិស័យសង្គមកិច្ចអនុវត្តបាន ៦៧៩.០៣៤ លានរៀល គឺស្មើនឹង ៣៧,១% នៃច្បាប់ ហិរញ្ញវត្ថុ និង វិស័យសេដ្ឋកិច្ចអនុវត្តបាន ១៥២.៩៧៦ លានរៀល គឺស្មើនឹង ៣៦,៥% នៃច្បាប់ហិរញ្ញវត្ថុ ។ បើពិនិត្យមើលការអនុវត្តចំណាយចរន្តតាមជំពូកវិញ (ដូចមានក្នុងតារាងឧបសម្ព័ន្ធ II-ខ ជូនភ្ជាប់មកជាមួយ) ឃើញថា ជំពូក ៦៤ (បន្ទុកបុគ្គលិក) អនុវត្តបាន ៩៣៦.០៨៩ លានរៀល គឺស្មើនឹង ៤៤,៨% នៃច្បាប់ហិរញ្ញវត្ថុ ជំពូក ៦០ (ការទិញ) អនុវត្តបាន ២៧៦.០៣២ លានរៀល គឺស្មើនឹង ៣៣,៩% ជំពូក ៦១ (សេវាខាងក្រៅ) អនុវត្តបាន ១៤៣.០៨៦ លានរៀល គឺស្មើនឹង ៤៧,១% នៃច្បាប់ហិរញ្ញវត្ថុ ជំពូក ៦២(សេវាខាងក្រៅផ្សេងៗ) អនុវត្តបាន ១១៦.០៦៦ លានរៀល គឺស្មើនឹង ៣៩,៨% នៃច្បាប់ហិរញ្ញវត្ថុ និង ជំពូក ៦៥ (ឧបត្ថម្ភធន និងជំនួយសង្គម) អនុវត្តបាន ៨៦៦.៧០៥ លានរៀល គឺស្មើនឹង ៨៦,៩% នៃច្បាប់ហិរញ្ញវត្ថុ ។

៩- ជារួមឃើញថាចំណូលសរុបឆ្លងកាត់រតនាគារជាតិក្នុងឆមាសទី ១ ឆ្នាំ ២០១០ អនុវត្តបាន ២.៩០៨.០១១ លានរៀល រីឯចំណាយសរុបឆ្លងកាត់រតនាគារជាតិអនុវត្តបាន ២.៧៣១.២៤០ លានរៀល ។ កត្តានេះបាននាំឱ្យការអនុវត្តថវិកា ឆមាសទី ១ ឆ្នាំ ២០១០ មានអតិរេកប្រមាណ ១៧៦.៧៧១ លានរៀល ។

## III. ការប៉ាន់ស្មានការអនុវត្តថវិកាប្រចាំឆ្នាំ ២០១០

១០- ផ្អែកលើលទ្ធផលនៃការអនុវត្តចំណូល-ចំណាយក្នុងឆមាសទី ១ និងការព្យាករណ៍នៃស្ថានភាពសេដ្ឋកិច្ច និងអាជីវកម្មនៅក្នុងឆមាសទី ២ នៃឆ្នាំ ២០១០ បានបង្ហាញថា វិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោកបានកំពុងបន្តជះឥទ្ធិពលជាអវិជ្ជមានមកលើការអនុវត្តថវិកាឆ្នាំ ២០១០ នៅឡើយ ជាពិសេសលើការប្រមូលចំណូល ដែលតាមការប៉ាន់ស្មានគឺចំណូលសរុបឆមាសទី ២ នឹងអាចសម្រេចបានប្រមាណ ៤៧,៤% នៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដែលក្នុងនោះ ចំណូលពន្ធ និងរដ្ឋាករ នឹងអាចសម្រេចបានប្រមាណ ៥១% ចំណូលពន្ធដារ នឹងអាចសម្រេចបានប្រមាណ ៤០% ចំណូលមិនមែនសារពើពន្ធ នឹងអាចសម្រេចបានប្រមាណ ៥១,៨% និង ចំណូលមូលធន នឹងអាចសម្រេចបានប្រមាណ ៥៣,១% ។ កត្តានេះ នឹងធ្វើឱ្យការអនុវត្តចំណូលប្រចាំឆ្នាំ ២០១០ នឹងអាចសម្រេចបានប្រមាណ ៩៥,១% នៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ គឺទាបជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ៣០២ ពាន់

លានរៀល ដែល ក្នុងនោះ ចំណូលគយ និងរដ្ឋាករ នឹងអាចសម្រេចបានប្រមាណ ៩៧,៨% ចំណូលពន្ធដារ នឹងអាចសម្រេចបានប្រមាណ ៨៥% ចំណូលមិនមែនសារពើពន្ធនឹងអាចសម្រេចបានប្រមាណ ១១១,៤% និង ចំណូលមូលធន នឹងអាចសម្រេចបាន ៩២,៦% ។

មូលធនអាចនឹងអនុវត្តបាន ៩៥,១% ។

១២- ផ្អែកតាមការប៉ាន់ស្មាននេះ ការអនុវត្តចំណូល-ចំណាយប្រចាំឆ្នាំ ២០១០ (ដូចមានក្នុងតារាង ឧបសម្ព័ន្ធ III ជូនភ្ជាប់មកជាមួយ) តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ នឹងមានឱនភាពសាច់ប្រាក់ ប្រមាណ ២៨៦ ពាន់លានរៀល ដែលកត្តានេះនឹងនាំឱ្យឱនភាពថវិកាសរុបកើនឡើងពី ៥,៣% នៃផសស ដែលបានគ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ មក ៦% នៃផសស ។

## IV. សន្និដ្ឋាន

១៣- បើទោះជាសេដ្ឋកិច្ចនៅក្នុងឆ្នាំ ២០១០ នេះ មានការងើបឡើងវិញ ដែលតាមការព្យាករណ៍ថា នឹងមានកំណើន ៥,៥% ក៏ដោយ ក៏មិនទាន់មានបច្ច័យល្អដល់ការអនុវត្តថវិកានៅឡើយ ជាពិសេសការអនុវត្ត ចំណូលដែលតាមការប៉ាន់ស្មាន ការអនុវត្តចំណូលប្រចាំឆ្នាំ ២០១០ នឹងអាចសម្រេចបានប្រមាណ ៩៥,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ គឺទាបជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ៣០២ ពាន់លានរៀល ដែលក្នុងនោះ ចំណូលគយ និងរដ្ឋាករនឹងអនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ៥៨ ពាន់លានរៀល ចំណូលពន្ធដារនឹងអនុវត្តបាន ទាបជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ៣១២ ពាន់លានរៀល ចំណូលមិនមែនសារពើពន្ធនឹងអនុវត្តបានខ្ពស់ជាង ច្បាប់ហិរញ្ញវត្ថុប្រមាណ ៩៧ ពាន់លានរៀល និង ចំណូលមូលធននឹងអនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ប្រមាណ ៣០ ពាន់លានរៀល ។ រីឯតម្រូវការចំណាយអាចនឹងអនុវត្តបានរហូតដល់ ៩៩,៩% ធៀបនឹងច្បាប់ ហិរញ្ញវត្ថុ ។

១៤- ប្រការនេះ ទាមទាឱ្យរាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ខ្ពស់ និងត្រូវចាត់វិធានការឱ្យបាន សមស្រប ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ដើម្បីរក្សាការប្រមូលចំណូលគយ និងរដ្ឋាករ និង ចំណូលពន្ធដារ កុំឱ្យធ្លាក់ចុះបន្ថែមទៀត ទន្ទឹមនឹងធ្វើអាទិភាពកម្ម និងវិចារណកម្មចំណាយ ក្នុងរយៈពេល ៤ ខែចុងក្រោយ នៃឆ្នាំ ២០១០នេះ ហើយការរៀបចំ និងការគ្រប់គ្រងថវិកាក្នុងឆ្នាំ ២០១១ ត្រូវតម្រឹម និងអនុវត្ត ឱ្យមានប្រសិទ្ធភាព ក្នុងគោលដៅរក្សាតុល្យភាព និង ចីរភាពថវិកា ក្នុងរយៈពេលមធ្យម និងរក្សាស្ថិរភាពសាច់ ប្រាក់ ឱ្យស្ថិតក្នុងកម្រិតសមរម្យមួយ ។

**ទី១: ទិដ្ឋានការចំណូលជាអតិភាព**

**ក. ចំណូលគយ និងរដ្ឋាករ:**

- ជំរុញដាក់ឱ្យអនុវត្តនូវគោលនយោបាយជាតិពាក់ព័ន្ធនឹងការងារទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធឱ្យបានឆាប់ ជាពិសេសកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី ភារកិច្ច ដែនសមត្ថកិច្ច និងការគ្រប់គ្រងមន្ត្រីរាជការគយដែលទទួលបន្ទុកការងារទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធគ្រប់ថ្នាក់ ។
- បន្តពង្រឹងកិច្ចសហការគយ ក៏ដូចជាជាមួយស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ជាពិសេសអាជ្ញាធរដែនដី និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដើម្បីទប់ស្កាត់ និងបង្ក្រាបការរត់គេចពន្ធផលិតផលគេលសិសា យានយន្ត និងបណ្តាទំនិញមានវេទយិតភាពចំណូល ឱ្យមានប្រសិទ្ធភាពខ្ពស់ ជាពិសេសនៅតាមតំបន់សមុទ្រ និងនៅចុងទី រួមទាំងការជំរុញដាក់ឱ្យដំណើរការពេញលេញនូវអង្គភាពនាវាចរណ៍គយ ក៏ដូចជាបង្កើតនូវសាខាគយ និងរដ្ឋាករឱ្យប្រចាំនៅគ្រប់ភូមិសាស្ត្ររាជធានី-ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ឈានទៅគ្របដណ្តប់ទូទាំងដែនគយជាតិ ។
- កែសម្រួលការគ្រប់គ្រងផលិតផលគេលសិលានាំចូលឱ្យមានភាពច្បាស់លាស់ងាយស្រួលក្នុងការកំណត់មុខសញ្ញាល្មើស និងការបង្ក្រាបរបស់យន្តការបង្ក្រាបកណ្តាលទី និងចុងទី រួមមានការគ្រប់គ្រងធុរជន ការគ្រប់គ្រងលិខិតដឹកជញ្ជូន និងការតម្រូវឱ្យចែកចាយតែតាមស្ថានីយ៍ដែលមានម៉ាកសញ្ញា ផលិតផលនាំចូលច្បាស់លាស់តែប៉ុណ្ណោះ ព្រោះជាប្រភេទទំនិញកំណត់ពិសេសតាមច្បាប់ជាធរមាន ។
- ពិនិត្យស៊ីជំរៅគោលនយោបាយពន្ធអាករគយ ឈានទៅកែសម្រួលអត្រាអាករលើទំនិញនាំចេញនាំចូលមួយចំនួន ជាពិសេសការនាំចេញកៅស៊ូ ដើម្បីរក្សាតុល្យភាពចំណូលដែលបាត់បង់ដោយសារ ការបញ្ចុះអត្រាពន្ធគយ តាមស្មារតីនៃកិច្ចព្រមព្រៀងពាណិជ្ជ-កម្មសេរីនានា ក៏ដូចជាឈានទៅកាត់បន្ថយអំពើរត់ពន្ធ តាមរយៈការកាត់បន្ថយគំលាតតម្លៃ ទំនិញរសើបលក់រាយនាតំបន់ព្រំដែនជាមួយប្រទេសជិតខាង ។ គោលនយោបាយនេះក៏អាចពិនិត្យឡើងវិញផងដែរ ក្នុងគោលបំណងនៃការអនុវត្តតម្លៃគិតពន្ធគយ តាមតម្លៃចម្លងការនៃកិច្ចព្រមព្រៀង GATT ឱ្យបានល្អ ជាពិសេសលើផលិតផលគេលសិលា និងទំនិញវេទយិតផ្សេងទៀត ។

**ខ. ចំណូលពន្ធដារ:**

- ធ្វើជំរឿនអ្នកជាប់ពន្ធនៅតាមរាជធានី-ខេត្ត ក្នុងនោះមានការធ្វើជំរឿនសហគ្រាស យានយន្ត អចលនទ្រព្យ និងដីធ្លីមិនប្រើប្រាស់ សំដៅពង្រីកមូលដ្ឋានជាប់ពន្ធប្រមូលពន្ធឱ្យអស់លទ្ធភាព ។
- រៀបចំអនុវត្តច្បាប់ជាធរមាន ដោយរៀបចំលិខិតបទដ្ឋានដើម្បីដាក់អនុវត្ត ÷

+ បទប្បញ្ញត្តិនៃច្បាប់ស្តីពីពន្ធលើអចលនទ្រព្យ

+ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញមូលធន

+ បទប្បញ្ញត្តិស្តីពីពន្ធលើភតិសន្យា ។ល។

- រៀបចំគោលនយោបាយសារពើពន្ធ ក្នុងនោះមានការរៀបចំ ÷

+ គម្រូសន្ធិសញ្ញាស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា

+ ច្បាប់ស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត

+ ច្បាប់ស្តីពីពន្ធលើប្រតិបត្តិការធនធានរ៉ែ ជាអាទិ៍មាន រ៉ែមាស និងលោហធាតុ និងត្បូងថ្មមាន តម្លៃដទៃទៀត ។

- អប់រំពន្យល់ណែនាំ ដោយផ្ទាល់ និងតាមរយៈការផ្សព្វផ្សាយសេចក្តីជូនដំណឹង និងសៀវភៅណែនាំនានា ដើម្បីឱ្យអ្នកជាប់ពន្ធបានយល់ច្បាស់ពីកាតព្វកិច្ចរបស់ខ្លួន គោរពប្រតិបត្តិច្បាប់ពន្ធបានល្អ ប្រសើរដោយស្ម័គ្រចិត្ត និងបង់ប្រាក់ពន្ធបានត្រឹមត្រូវ ។

- អនុវត្តវិធានការដាក់បង្ខំ ក្នុងនោះមានការធ្វើសវនកម្ម និងការទារបំណុលពន្ធដែលត្រូវបន្តវិធានការតឹងទារបំណុលពន្ធឱ្យបានខ្លាំងក្លា ចំពោះអ្នកជាប់ពន្ធដែលជំពាក់បំណុលពន្ធច្រើន ហើយមិនអើពើអំពីការទូទាត់ឱ្យបានជ្រះស្រឡះ ។ វិធានការតឹងទារ ដែលអគ្គនាយកដ្ឋានពន្ធដារបាន និងកំពុងបន្តអនុវត្តរួមមាន ÷

+ សហការជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ និង ធនាគារ ឱ្យឃាត់ទុកគណនីអ្នកជំពាក់បំណុលពន្ធ ។

+ ស្នើសុំកិច្ចសហការពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បញ្ឈប់ប្រតិបត្តិការនាំចេញ- នាំចូល ចំពោះអ្នកជំពាក់បំណុលពន្ធដែលមានសកម្មភាពនាំចេញ-នាំចូល ។

+ ស្នើសុំឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ធ្វើការព្យួរទុកការពិនិត្យឯកសារវិនិយោគរបស់សហគ្រាស ដែលជំពាក់បំណុលពន្ធ ។

+ ព្យួរទុកការផ្ទេរកម្មសិទ្ធិកាន់កាប់អចលនទ្រព្យ

+ ដំណើរការក្តីបំណុលពន្ធទៅតុលាការចំពោះសហគ្រាសរឹងរូសមួយចំនួន ។ល។

**គ. ចំណូលមិនមែនសារពើពន្ធៈ**

- ជំរុញការអនុវត្តជាប្រព័ន្ធនូវកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ២ ក្នុងការកៀរគរចំណូលមិនមែនសារពើពន្ធ ដែលក្រសួង-ស្ថាប័នប្រមូលចំណូលត្រូវតែដើរតួជាតួអង្គគន្លឹះក្នុងការអនុវត្ត ពិសេសចំណូលទាំងអស់ត្រូវតែបង់ចូលគណនីរតនាគារជាតិ និងឱ្យបានតាមពេលវេលាកំណត់ ។

- បន្តស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយបន្តជំរុញការអនុវត្តនូវផែនការសកម្មភាព និងបណ្តាវិធានការ ដើម្បីតឹងទារបំណុលទាំងអស់នេះ តាមគ្រប់មុខសញ្ញាទាំងអស់ ។ ក្នុងនេះ ត្រូវផ្តោតការយកចិត្ត

ទុកដាក់ ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីប្រៃសណីយ៍ និង ទូរគមនាគមន៍ អាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និងចំណូលពីការជួល រោងចក្រសហគ្រាស និងទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និងទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតឹងទារចំណូល ដោយតម្រូវឱ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់បង់ចំណូលដោយត្រង់ទៅ ក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិនៃកម្ពុជា ហើយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការបង់ចំណូលនេះ ។
- បន្តអនុវត្តប្រកបដោយប្រសិទ្ធភាព នូវវិធានការពង្រឹងការប្រមូលចំណូលពីការជួល ឬលក់អចលនទ្រព្យ រួមទាំងការពង្រឹងនីតិវិធីនៃការជួល និង ការចុះកិច្ចសន្យាចំណូលពីសហគ្រាសសាធារណៈ តាមរយៈការពង្រឹងក្របខ័ណ្ឌនៃការគ្រប់គ្រងសហគ្រាស និងចំណូលពីការគ្រប់គ្រងធនធានធម្មជាតិគ្រប់ប្រភេទ ។
- បន្តជំរុញការអនុវត្តប្រព័ន្ធដែលផ្តល់អំណាចដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការអនុម័តជាចុងក្រោយ លើរាល់កិច្ចព្រមព្រៀង និង កិច្ចសន្យាសម្បទានគ្រប់ប្រភេទ ដើម្បីបង្កើនចំណូលពីសម្បទានរបស់រដ្ឋ និងដើម្បីការពារផលប៉ះពាល់អាក្រក់ដល់ថវិកាជាតិ។

**ទី២: វិធានការចំណាយ**

- បញ្ឈប់រាល់ការទិញនូវសង្ហារឹមរដ្ឋបាលប្រណិតៗ និង ពិចារណាលើការកាត់បន្ថយចំណាយជំពូក ៦០ (ការទិញ) ចំនួន ៦% លើឥណទានថ្មីក្រោយកែសម្រួល លើកលែងតែក្រសួងអាទិភាពមួយចំនួន ។
- ការប្រើប្រាស់ទូរស័ព្ទអចល័ត គួរអោយមានការឆ្លងកាត់កន្លែងត្រួតពិនិត្យ (Standard) មួយរបស់ក្រសួង- ស្ថាប័ននីមួយៗ ដើម្បីជៀសវាងការប្រើប្រាស់ទូរស័ព្ទក្រៅផ្លូវការ ដែលមិនបម្រើឱ្យផលប្រយោជន៍រួម ។
- ត្រូវចាត់វិធានការលើការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនរបស់រដ្ឋ ដោយត្រូវធ្វើការប្រមូលផ្ដុំទុក ដាក់ជាដាច់ខាតក្នុងយានដ្ឋាន ឬនៅក្នុងបរិវេណក្រសួង- ស្ថាប័ន សម្រាប់រាល់ថ្ងៃឈប់សម្រាក លើកលែងតែមានតម្រូវការបេសកកម្មផ្លូវការខាងក្រៅខេត្ត។ ហាមប្រើប្រាស់មធ្យោបាយដឹកជញ្ជូន របស់រដ្ឋសម្រាប់បម្រើផលប្រយោជន៍ផ្ទាល់ខ្លួនជាដាច់ខាត ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំសារាចរណែនាំលម្អិតអំពីករណីនេះ ។
- ក្រសួង- ស្ថាប័នទាំងអស់ត្រូវចាត់វិធានការឱ្យបានម៉ឺងម៉ាត់ លើការប្រើប្រាស់ឧបករណ៍អគ្គិសនី ដែលមិនសមស្រប និង មិនអនុញ្ញាតិអោយមានការតំឡើងអាំងតង់ស៊ីតេចរន្ត

បន្ថែម និងមិនអនុញ្ញាតិឱ្យបំពាក់បន្ថែមនូវឧបករណ៍ត្រជាក់ក្នុងអាគាររដ្ឋបាល ដែលមានស្រាប់ ។

- សន្សំសំចៃអោយបានកំរិតអតិបរមាលើការចំណាយជំពូក ៦១-៦២ ដោយកាត់បន្ថយចំនួន ៦% លើឥណទានថ្មីក្រោយកែសម្រួល ជាពិសេសពិចារណាលើការកាត់បន្ថយចំណាយខ្ជះខ្ជាយមួយចំនួន សម្រាប់កិច្ចប្រជុំ ទទួលភ្ញៀវ និងសិក្ខាសាលាផ្សេងៗ ។
- បន្តធ្វើវិចារណៈកម្មលើការចំណាយបន្ទុកបុគ្គលិក ជំពូក ៦៤ ដោយមិនអនុញ្ញាតិឱ្យមានការទទួលប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗលើសពីមួយកន្លែង ។
- ពន្យឺតការទូទាត់ចំណាយវិនិយោគ ដែលហិរញ្ញប្បទានដោយថវិកាជាតិ ។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើ សូម**សម្តេចអគ្គមហាពញាចក្រីប្រធានរដ្ឋសភា** មេត្តាជ្រាប និងចាត់ទុកជារបាយការណ៍ជូនរដ្ឋសភាជ្រាបដ៏ខ្ពង់ខ្ពស់ ។

សូម **សម្តេចអគ្គមហាពញាចក្រីប្រធានរដ្ឋសភា** មេត្តាទទួលនូវគោរវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន:**
- ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា
- ឯកសារ- កាលប្បវត្តិ